# អនុស្សាវរីយ៍

(បទព្រហ្មគីតិ)

មើលនាយផ្កាយព្រិចៗ ភ្លឺរំលេចផ្ទៃវេហាស៍
គន់គាប់ជាប់នេត្រា ដួងតារាថ្លាព្រោងព្រាយ។
បងថាផ្កាយអាយជិត ល្អពេកពិតជាងនៅនាយ
ថាភ្នែកអូនពណ្ណរាយ ភ្លឺលើសផ្កាយឯនភា។
រត្តិកាលជឿនគ្រឿនទៅ រះឡើងនៅឯបូព៌ា
ត្រចង់វង់ច័ន្ទ្រា នាវេលាពេញបូណ៌មី។
ផង់ផូរចន្ទោភាស ថ្លាត្រចះរុងរង្សី
គ្រងលើនភាល័យ ច័ន្ទប្រពៃល្អប៉ប្រិម។
បងថាព្រះច័ន្ទល្អ ក៏ពុំស្មើអូនញញឹម
ច័ន្ទហោះខ្ពស់សន្ធឹម ម្តេចអាចផ្ទឹមស្មើរូបស្រី។
នៅនែបនិត្យជិតបង ផ្តៃផ្តោះផ្គងសងសម្តី
ច័ន្ទគ្រាន់ចោលរស្មី ជួយឱ្យថ្លៃយល់ស្រីច្បាស់។
...
យប់នេះយល់ច័ន្ទ្រា លើមេឃាថ្លាស្រលះ
ចិត្តគិតដល់រឿងចាស់ ដែលនិរាសប្រាសទីទៃ។
ពេលឆ្លងកន្លងហួស ពុំអាចជួសឱ្យវិលវៃ
ដូចនាគ្រាដើមនៃ តែហរទ័យស្រីស្រស់ថ្លា។
បរិបូរណ៍ពោរដួងចិត្ត ដោយអតីតអនុស្សារ
អរគុណព្រេងវាសនា ដែលបានចារឱ្យជួបជូន។

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**